# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ១៧១ MIH / 2016

## ប្រកាស
## ស្តីពី
## ការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម ស្ថិតក្រោមកិច្ចសហប្រតិបត្តិការ សម្របសម្រួល ការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជា ទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ៤៥១MIH/2014 ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម
- បានឃើញប្រកាសរួមលេខ ៧១៧សហវ-ប្រក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមការងារចាំបាច់របស់ក្រសួង

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.**_

ប្រកាសនេះ កំណត់ពីនីតិវិធីសម្រាប់ការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម ស្ថិតក្រោមកិច្ចសប្រតិបត្តិការសម្របសម្រួលការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជា ដែលទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com

ជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន ដោយអនុលោមតាមមាត្រា១៣០ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

## ផ្នែកទី២
## ការសម្របសម្រួលផ្តល់ប្រកាសនីយបត្រតក្កកម្ម

**ប្រការ២.**_

ការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម ស្ថិតក្រោមកិច្ចសហប្រតិបត្តិការសម្របសម្រួលផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជា ដែលទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន ត្រូវធ្វើនៅនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

**ប្រការ៣.**_

អ្នកដាក់ពាក្យសុំ អាចស្នើសុំពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម បានចំពោះតែពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលដាក់នៅក្រសួងឧស្សហកម្ម និងសិប្បកម្ម ដោយប្រើប្រាស់លទ្ធផលស្រាវជ្រាវ និងពិនិត្យតក្កកម្ម ដែលត្រូវបានធ្វើឡើងដោយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន។

**ប្រការ៤.**_

ការស្នើសុំពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម អាចត្រូវបានទទួលយកចំពោះតែពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលបានដាក់នៅក្រសួងឧស្សហកម្ម និងសិប្បកម្ម ស្របតាមលក្ខខណ្ឌដូចខាងក្រោម៖

១- ពាក្យសុំប្រកាសនីយបត្រតក្កកម្ម ត្រូវមានការប្រកាសសិទ្ធិអាទិភាព ក្រោមអនុសញ្ញាក្រុងប៉ារីសស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ផ្អែកលើមូលដ្ឋានពាក្យសុំប្រកាសនីយបត្រតក្កកម្មជប៉ុន ឬ

២- ពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលបម្រើជាមូលដ្ឋានសម្រាប់ប្រកាសសិទ្ធិអាទិភាព ក្រោមអនុសញ្ញាក្រុងប៉ារីស ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ដោយផ្អែកលើមូលដ្ឋាននៃពាក្យសុំប្រកាសនីយបត្រតក្កកម្មជប៉ុន រួមទាំងពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលស្ថិតក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ដែលចូលក្នុងដំណាក់កាលជាតិ ឬ

៣- ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ដែលមានមូលដ្ឋានដូចគ្នាទៅនឹង ពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មសម្រាប់ប្រកាសសិទ្ធិអាទិភាព ក្រោមអនុសញ្ញាក្រុងប៉ារីស ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ដោយផ្អែកលើមូលដ្ឋាននៃពាក្យសុំរបស់អង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន រួមទាំងពាក្យសុំប្រកាសនីយបត្រតក្កកម្ម ដែលស្ថិតក្រោមសន្ធិសញ្ញាសហប្រតិបត្តិការ ប្រកាសនីយបត្រតក្កកម្ម ដែលចូលក្នុងដំណាក់កាលជាតិ។

**ប្រការ៥.**_

ក្នុងការសុំពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម អ្នកដាក់ពាក្យសុំត្រូវប្រើទម្រង់ពាក្យសុំដូចបានភ្ជាប់ក្នុងឧបសម្ព័ន្ធ១ និងត្រូវបំពេញទិន្ន័យដូចខាងក្រោម៖



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com

ក- ចំណងជើងតក្កកម្ម

ខ- កាលបរិច្ឆេទដាក់ពាក្យស្នើសុំ

គ- លេខសំណុំលិខិតស្នើសុំ

ឃ- ឈ្មោះអ្នកដាក់ពាក្យសុំ

ង- សំណុំលិខិតស្នើសុំទាក់ទងទៅនឹងអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន និង

ច- ឯកសារភ្ជាប់មួយចំនួនទៀតដែលត្រូវផ្តល់ដូចខាងក្រោម៖

- ច្បាប់ចម្លងនៃពាក្យសុំប្រកាសនីយបត្រតក្កកម្មជប៉ុន ដែលបានបោះពុម្ពផ្សាយក្នុងព្រឹត្តបត្រប្រកាសនីយបត្រតក្កកម្ម និងមានការបញ្ជាក់ដោយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន។
- តារាងអំពីការផ្លាស់ប្តូរសេចក្តីអះអាង។
- បកប្រែជាភាសាអង់គ្លេសនូវសេចក្តីអះអាង និងលក្ខណៈបច្ចេកទេស ដែលពិពណ៌នានៅក្នុងព្រឹត្តបត្រប្រកាសនីយបត្រតក្កកម្ម។
- បកប្រែជាភាសាខ្មែរនូវសេចក្តីអះអាង និងលក្ខណបច្ចេកទេស ដែលពិពណ៌នានៅក្នុងព្រឹត្តបត្រប្រកាសនីយបត្រតក្កកម្ម។ អ្នកដាក់ពាក្យសុំត្រូវផ្តល់សេចក្តីបកប្រែក្នុងរយៈពេលប្រាំមួយ (៦) ខែ ចាប់ពីកាលបរិច្ឆេទនៃការស្នើសុំពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម។

**ប្រការ៦.**

ការស្នើសុំពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម អាចទទួលយកបានចំពោះតែប្រកាសនីយបត្រតក្កកម្ម ដែលបានដាក់នៅអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន ហើយមានលក្ខខណ្ឌដូចខាងក្រោម៖

១- ត្រូវតែជាពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មជប៉ុន ដែលមានកាលបរិច្ឆេទដំបូងបង្អស់ ដូចគ្នានឹងពាក្យស្នើសុំដែលបានដាក់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម

២- ត្រូវតែមានទំនាក់ទំនងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ដែលបានផ្តល់ប្រកាសនីយបត្រតក្កកម្ម ជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន

៣- ត្រូវតែមានសេចក្តីអះអាង ក្នុងពាក្យស្នើសុំដែលបានដាក់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ហើយមានសេចក្តីអះអាងមួយ ឬច្រើនដូចទៅនឹងសេចក្តីអះអាង ដែលមាននៅក្នុងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មជប៉ុន ដែលបានផ្តល់ប្រកាសនីយបត្រតក្កកម្ម ដោយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន។

**ប្រការ៧.**

ការការពន្លឿនផ្តល់ប្រកាសនីយបត្រតក្កកម្ម ស្ថិតក្រោមកិច្ចសហប្រតិបត្តិការសម្របសម្រួល ការផ្តល់ប្រកាសនីយបត្រតក្កកម្មកម្ពុជា ទាក់ទងទៅនឹងពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្ម ជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន ពុំមានការបង់កម្រៃសេវាឡើយ។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៤
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៥៤
អ៊ីមែល: mih.smcabinet@gmail.com

# ផ្នែកទី៣

# អវសានប្បញ្ញត្តិ

**ប្រការ៨.**_

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.**_

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ប្រធាននាយកដ្ឋាននីតិកម្ម គ្រប់អង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រធានមន្ទីរឧស្សហកម្ម និងសិប្បកម្មរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**__កន្លែងទទួល__ ៖**

- ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- ដូចប្រការ៩
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ( ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៥៤
អ៊ីម៉ែល: mih.smcabinet@gmail.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft

លេខ : ........................ឧស ........................

ឧបសម្ព័ន ១ (ពគ្រ)
ANNEX 1 (CPC)

# ពាក្យសុំប្រកាសនីយតក្កកម្ពុជា
# Request Form

| កម្មវត្ថុ៖ សំណើសុំពន្លឿនលើការផ្តល់ប្រកាសនីយបត្រតក្កកម្មជប៉ុន នៅកម្ពុជា<br>Subject : Request for an accelerated decision under the CPG | សម្រាប់មន្ត្រីកាន់កាប់បញ្ជី<br>For Registrar |
|---|---|
| | កាលបរិច្ឆេទទទួល :<br>Receiving Date |
| | លេខរបស់សំណុំលិខិតស្នើសុំ :<br>Application Number |
| | កាលបរិច្ឆេទសុំចុះបញ្ជី :<br>Filing Date |

លេខសំណុំសំណុំលិខិតស្នើសុំ/Patent Application number: ..............................................................

ការបរិច្ឆេទសុំចុះបញ្ជី/Date of filing :..............................................................

ចំណងជើងនៃតក្កកម្ម/Title of invention :..............................................................

..............................................................................................................................................

អ្នកដាក់ពាក្យសុំ/ Applicant : ..............................................................

ពាក្យស្នើសុំពន្លឿនលើការផ្តល់ប្រកាសនីយបត្រតក្កម្មជប៉ុនលេខ:........................................

Corresponding patent application number

ត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម/Attached Documents:

□ ច្បាប់ចម្លងនៃពាក្យសុំប្រកាសនីយបត្រតក្កកម្មជប៉ុន ដែលបានបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រប្រកាសនីយបត្រតក្កកម្ម និងមានការបញ្ជាក់ដោយអង្គភាពប្រកាសនីយបត្រ តក្កកម្មជប៉ុន។

□A copy of patent gazette in the corresponding JPO patent application, and its certification by the JPO

□ បកប្រែជាភាសាអង់គ្លេសនូវសេចក្តីអះអាង និងលក្ខណបច្ចេកទេស ដែលពិពណ៌នានៅក្នុងព្រឹត្តិបត្រប្រកាសនីយបត្រតក្កកម្ម។

□Translation of Claims and Specification described in the patent gazette in English

□ បកប្រែជាភាសាខ្មែរនូវសេចក្តីអះអាង និងលក្ខណបច្ចេកទេស ដែលពិពណ៌នានៅក្នុងព្រឹត្តិបត្រប្រកាសនីយបត្រតក្កកម្ម។

□Translation of Claims and Specification described in the patent gazette in Khmer (Translator must provide a self – declaration)

(ចំណាំ)អ្នកដាក់ពាក្យសុំត្រូវផ្តល់សេចក្តីបកប្រែក្នុងរយៈពេលប្រាំមួយខែ(៦)ចាប់ពីកាលបរិច្ឆេទនៃការស្នើសុំពន្លឿនលើការផ្តល់ប្រកាសនីយបត្រតក្កកម្ម(CPG)។

(Note) Applicant may submit the translation within six months of date on which the request of the CPG was filed.

□ តារាងអំពីការផ្លាស់ប្តូរសេចក្តីអះអាង/Claims correspondence table

ហត្ថលេខា/ Signature

______________________